ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤៣ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការចំពោះកិច្ចរៀបចំទទួលព្រះបរមសារីរិកធាតុ និងព្រះអរហន្តធាតុ ព្រមទាំងក្បួនធម្មយាត្រា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- បានឃើញអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការចំពោះកិច្ចរៀបចំទទួលព្រះបរមសារីរិកធាតុ និងព្រះអរហន្តធាតុ ព្រមទាំងក្បួនធម្មយាត្រា ដែលមានសមាសភាពដូចខាងក្រោម៖

១- សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជ ព្រះប្រធានកិត្តិយស

២- សម្តេចព្រះពោធិវង្សកិត្តិបណ្ឌិត **អំ លីមហេង** សម្តេចព្រះសង្ឃនាយករង ព្រះប្រធានកិត្តិយស

៣- ឯកឧត្តម **ចាយ បូរិន** រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ប្រធាន

៤- សម្តេចព្រះពុទ្ធជ័យមុនីបណ្ឌិត **ឃឹម សន** ព្រះប្រធានលេខាធិការដ្ឋានគណៈសង្ឃនាយក អនុប្រធាន

| | | | |
|---|---|---|---|
| ៥- ឯកឧត្តម | **ឃួ ស៊ីនឡុង** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៦- ឯកឧត្តម | **ជៀង អំ** | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៧- ឯកឧត្តម | **ឈិន កេតនា** | អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការនៃ<br>គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ | អនុប្រធាន |
| ៨- ឯកឧត្តម | **សៀង ឈុនទ្រី** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៩- ឯកឧត្តម | **ទូច ណារ៉ុថ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ១០- ឯកឧត្តមបណ្ឌិត | **ហ៊ីង សុវណ្ណា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ១១- ឯកឧត្តម | **សេង ទៀង** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី និងជានាយករង<br>ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១២- ឯកឧត្តម | **មៃ ស៊ីថន** | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី<br>និងជាពិធីការសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ១៣- ឯកឧត្តម | **ឃួង ស្រេង** | អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ១៤- ឯកឧត្តម | **គង់ សោភ័ណ្ឌ** | អភិបាល នៃគណៈអភិបាលខេត្តកណ្ដាល | អនុប្រធាន |
| ១៥- ឯកឧត្តមបណ្ឌិត | **ឃី សុវណ្ណរតនា** | រដ្ឋលេខាធិការក្រសួងការបរទេស<br>និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៦- ឯកឧត្តម | **ឈួរ សុបញ្ញា** | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៧- ឯកឧត្តម | **សេរី ជំនះ** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៨- ឯកឧត្តម | **គឹម គុណាវឌ្ឍន៍** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៩- ឯកឧត្តមវេជ្ជបណ្ឌិត | **សាន់ សាប់អី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២០- លោកជំទាវ | **នេត្រ តូម៉ារី** | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិកា |
| ២១- ឯកឧត្តម | **ប៉ាក់ សុខុម** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២២- ឯកឧត្តម | **សរ មុន្នី** | រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន<br>អាកាសចរណ៍ស៊ីវិល | សមាជិក |
| ២៣- ឯកឧត្តមបណ្ឌិត | **សេង សុមុនី** | រដ្ឋលេខាធិការប្រចាំការក្រសួងធម្មការនិងសាសនា | សមាជិក |
| ២៤- ឯកឧត្តម | **មាស សំណាង** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| ២៥- ឯកឧត្តម | **សាយ អំណាន** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| ២៦- ឯកឧត្តម | **សោម រតនា** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| ២៧- លោកជំទាវ | **មិន ចណ្ឌីណែត** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិកា |
| ២៨- ឯកឧត្តម | **នាក់ សំបូរ** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| ២៩- ឯកឧត្តម | **ណាត សុឆេត** | រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| ៣០- ឯកឧត្តម | **ម៉ឺន បុណ្យសារ៉ាត់** | អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| ៣១- ឯកឧត្តម | **ឡា ទិសេស** | អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា | សមាជិក |
| ៣២- ឯកឧត្តម | **រស់ វណ្ណី** | អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងធម្មការ<br>និងសាសនា | សមាជិក |
| ៣៣- ឯកឧត្តម | **ស៊ិន សុវណ្ណនិ** | អគ្គនាយកកិច្ចការសាសនា ក្រសួងធម្មការ<br>និងសាសនា | សមាជិក |

| | | | |
|---|---|---|---|
| ៣៤- ឯកឧត្តម | **ឡេង ម៉ុនដែន** | អគ្គលេខាធិការរងក្រសួងធម្មការនិងសាសនា | សមាជិក |
| ៣៥- លោកជំទាវ | **កែវ សុខពិសី** | អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិកា |
| ៣៦- លោកជំទាវ | **ហ៊ីន ភុសនី** | អភិបាលរងនៃគណៈអភិបាលខេត្តកណ្តាល | សមាជិកា |
| ៣៧- ឯកឧត្តម | **យិន សារ៉េន** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង | សមាជិក |
| ៣៨- លោកស្រី | **ឡុង បូណារេត** | អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ស្ពឺ | សមាជិកា |
| ៣៩- លោក | **ស្មួន សុធារ៉ា** | នាយករងខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា | សមាជិក |
| ៤០- តំណាងសហភាពសហព័ន្ធយុវជនកម្ពុជា ស.ស.យ.ក | | | សមាជិក។ |

**ប្រការ២ .–**

គណៈកម្មការនេះមានភារកិច្ចដូចតទៅៈ

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈសង្ឃនាយកទាំងពីរគណៈនៃព្រះរាជាណាចក្រកម្ពុជាដើម្បីរៀបចំទទួលព្រះបរមសារីរិកធាតុ និងព្រះអរហន្តធាតុ ព្រមទាំងក្បួនធម្មយាត្រា ឱ្យប្រព្រឹត្តទៅបានល្អប្រសើរ
- ពិនិត្យ និងលើកសំណើដោះស្រាយបញ្ហានានា ទាក់ទិននឹងការរៀបចំទទួលព្រះបរមសារីរិកធាតុ និងព្រះអរហន្តធាតុ ព្រមទាំងក្បួនធម្មយាត្រាខាងលើ
- រៀបចំកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងពិធីឱ្យបានល្អប្រសើរ និងប្រកបដោយសុវត្ថិភាព
- ផ្ញើលិខិតអញ្ជើញ រៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំ និងភ្ញៀវជាតិ អន្តរជាតិ ដែលអញ្ជើញចូលរួម
- លើកគម្រោង និងចាត់ចែងគ្រប់គ្រងចំណូល ចំណាយថវិកាជាតិ និងសប្បុរសជន ដើម្បីបម្រើឱ្យព្រឹត្តិការណ៍នេះប្រព្រឹត្តទៅបានដោយរលូន និងល្អប្រសើរ
- បំពេញភារកិច្ចជាក់ស្តែងផ្សេងទៀត តាមការចាំបាច់សម្រាប់បម្រើឱ្យពិធីទាំងមូល
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូននាយករដ្ឋមន្ត្រី តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី
- អនុវត្តនូវភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣ .–**

គណៈកម្មការនេះ ត្រូវបង្កើតអនុគណៈកម្មការ ដើម្បីជួយរៀបចំប្រព្រឹត្តទៅតាមប្រពៃណីព្រះពុទ្ធសាសនាឱ្យបានល្អប្រសើរ។

គណៈកម្មការនេះ អាចប្រើត្រាក្រសួងធម្មការនិងសាសនា ដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ៤ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣ រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ